**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ០៩ **អយក.**សប៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាដែលបានវិលត្រឡប់ពីប្រទេសថៃ ឱ្យសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនក្នុងប្រទេសកម្ពុជា ក្រោមឈ្មោះថា "អាហារូបករណ៍សម្តេចតេជោ"

ក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូននិស្សិតកម្ពុជា និងសាធារណជនទាំងអស់ជ្រាបថា៖ ចាប់តាំងពីមានការផ្ទុះអាវុធនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ រហូតដល់ព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ និស្សិតដែលបានវិលត្រឡប់ពីប្រទេសថៃមកកាន់ប្រទេសកម្ពុជាវិញមានចំនួន ៤២៣នាក់។ និស្សិតចំនួន**១៧២នាក់** ក្នុងចំណោម ៤២៣នាក់ បានស្នើសុំអាហារូបករណ៍ពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបន្តការសិក្សានៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនក្នុងប្រទេសកម្ពុជា។

ដោយមានការយកចិត្តទុកដាក់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** អាហារូបករណ៍ក្រោមឈ្មោះថា "**អាហារូបករណ៍សម្តេចតេជោ**" នឹងផ្តល់ជូននិស្សិតកម្ពុជាទាំង**១៧២នាក់** ឱ្យបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនក្នុងប្រទេសកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់និស្សិតកម្ពុជាទាំង**១៧២នាក់** សូមទាក់ទងគ្រឹះស្ថានឧត្តមសិក្សាដោយផ្ទាល់ ដើម្បីរៀបចំបែបបទ និងដាក់ពាក្យស្នើសុំចូលរៀន។ ក្រសួងអប់រំ យុវជន និងកីឡា ចាត់តាំងឯកឧត្តមបណ្ឌិត ហុង គឹមជាង អនុរដ្ឋលេខាធិការ ដែលមានលេខទូរសព្ទ និងតេឡេក្រាម៖ +85512225303 ដើម្បីជួយសម្របសម្រួលជូនដល់និស្សិតកម្ពុជា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមនិស្សិតកម្ពុជា និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០២៥

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh